## សេចក្តីប្រកាសព័ត៌មាន

## ស្តីពី

## ជំនួបពិភាក្សារវាងឯកឧត្តមបណ្ឌិត អូន ព័ន្ធមុនីរ័ត្ន ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ជាមួយ ឯកឧត្តម George Edgar ឯកអគ្គរដ្ឋទូត និងជាប្រធានប្រតិភូសហភាពអឺរ៉ុបនៅកម្ពុជា

នាព្រឹកថ្ងៃទី១១ ខែសីហា ឆ្នាំ២០១៦ នៅទីស្តីការក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ឯកឧត្តមបណ្ឌិត **អូន ព័ន្ធមុនីរ័ត្ន** ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ បានអនុញ្ញាតឱ្យឯកឧត្តម George Edgar ឯកអគ្គរដ្ឋទូត និងជាប្រធានប្រតិភូសហភាពអឺរ៉ុប និងក្រុមការងារចូលជួបសំដែងការគួរសម និងពិភាក្សាការងារស្តីពីកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ដំណាក់កាលទី៣។

ជាកិច្ចចាប់ផ្តើម ឯកឧត្តម George Edgar ឯកអគ្គរដ្ឋទូត និងជាប្រធានប្រតិភូសហភាពអឺរ៉ុប ក៏បានថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅជូនចំពោះ **ឯកឧត្តមបណ្ឌិតទេសរដ្ឋមន្ត្រី** ដែលបានចំណាយពេលដ៏មមាញឹក និងមានតម្លៃក្នុងជំនួបសំដែងការគួរសមនេះ។ ទន្ទឹមនេះ ឯកឧត្តម George Edgar ក៏បានលើកនូវចំណុចពិភាក្សា ដោយផ្តោតជាសំខាន់លើ (១)-ការត្រួតពិនិត្យ និងតាមដានការអនុវត្តផែនការសកម្មភាពរួម ដំណាក់កាលទី៣, (២)-ការកែទម្រង់លទ្ធកម្មសាធារណៈ, (៣)-ការកសាងសមត្ថភាពសម្រាប់ដំណាក់កាលទី៣, (៤)-តម្លាភាពថវិកា និង (៥)-ការវិភាជថវិកាសម្រាប់គាំទ្រគណៈកម្មាធិការសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យថ្នាក់ក្រោមជាតិ ។

ជាកិច្ចឆ្លើយតប **ឯកឧត្តមបណ្ឌិតទេសរដ្ឋមន្ត្រី** បានផ្តល់កិច្ចស្វាគមន៍យ៉ាងកក់ក្តៅចំពោះ ឯកឧត្តម George Edgar និងក្រុមការងារ និងបានវាយតម្លៃខ្ពស់ចំពោះសហភាពអឺរ៉ុបដែលបានផ្តល់ជាហិរញ្ញប្បទានគាំទ្រកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈតាំងពីដើម និងការអភិវឌ្ឍនៅកម្ពុជា រហូតមក។

ជាមួយគ្នានេះ **ឯកឧត្តមបណ្ឌិតទេសរដ្ឋមន្ត្រី** បានលើកនូវវឌ្ឍនភាពការអនុវត្តកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ និងយន្តការសម្រាប់ត្រួតពិនិត្យនិងតាមដានការអនុវត្ត ដូចខាងក្រោម÷

- សមិទ្ធផលសំខាន់ៗ÷ អនុវត្តកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ក្នុងរយៈពេល ១០ ឆ្នាំកន្លងមកនេះ រាជរដ្ឋាភិបាលកម្ពុជា សម្រេចបានលទ្ធផល ដូចជា បានកែប្រែពីស្ថានភាពខ្វះខាតសាច់ ទៅជាអតិរេកសាច់ប្រាក់, លុបបំបាត់បំណុលកកស្ទះ, មន្ត្រីរាជការបានបើកប្រាក់បៀវត្សទាន់ពេលវេលា ពោលគឺយ៉ាងយូរនៅសប្តាហ៍ទី៤ ក្នុងខែនីមួយៗ និងដំឡើងបៀវត្សឱ្យមន្ត្រីរាជការឱ្យបាន ១ លានរៀលនៅឆ្នាំ២០១៨។
- យន្តការដាមតាននៃផែនការសកម្មភាពដំណាក់កាលទី៣÷ ការតាមដានវឌ្ឍនភាពកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈប្រចាំត្រីមាស និងប្រចាំឆ្នាំក្នុងកម្រិតគណៈកម្មការកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈគណៈកម្មាធិការដឹកនាំការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ និងក្រុមការងារបច្ចេកទេសរវាងរាជរដ្ឋាភិបាល និងដៃគូអភិវឌ្ឍន៍។

- ការងារកែទម្រង់ប្រព័ន្ធថវិកាថ្មី “**ការអនុវត្តថវិកាកម្មវិធី**”៖ រាជរដ្ឋាភិបាលបានសម្រេចដាក់ឱ្យក្រសួង ស្ថាប័នអនុវត្តថវិកាកម្មវិធីពេញលេញ ជាដំណាក់កាលៗ ដោយក្រសួង ស្ថាប័នចំនួន ១០ អនុវត្តនៅឆ្នាំ២០១៥, ក្រសួង ស្ថាប័នចំនួន ១៥ អនុវត្តនៅឆ្នាំ២០១៦, ក្រសួង ស្ថាប័នចំនួន ១១ អនុវត្តនៅឆ្នាំ២០១៧ និងក្រសួង ស្ថាប័នចំនួន ៣ អនុវត្តនៅឆ្នាំ២០១៨។ ទន្ទឹមនឹងនេះ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុបានសម្រេចកែសម្រួលសៀវភៅ “**ទស្សនាទានស្តីពីទិសដៅយុទ្ធសាស្ត្រនៃការកែទម្រង់ប្រព័ន្ធថវិកាកម្ពុជា ២០១៣-២០២០**” ទៅជា “**ផែនការយុទ្ធសាស្ត្រនៃការកែទម្រង់ប្រព័ន្ធថវិកាកម្ពុជាឆ្នាំ២០១៧-២០២៥**”។
- កិច្ចលទ្ធកម្មសាធារណៈ ៖ ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ បាននិងកំពុងរៀបចំលិខិតបដ្ឋានគតិយុត្តិបន្ថែមក្នុងន័យពង្រឹងដំណើរការ និងតម្លាភាពនៃកិច្ចលទ្ធកម្មសាធារណៈ។ ជាពិសេស អគ្គនាយកដ្ឋានលទ្ធកម្មសាធារណៈ បានផ្សព្វផ្សាយផែនការលទ្ធកម្មសាធារណៈគ្រប់ក្រសួង ស្ថាប័ន និងការប្រគល់កិច្ចសន្យានៅលើគេហទំព័ររបស់អគ្គនាយកដ្ឋានផ្ទាល់។
- តម្លាភាពថវិកា៖ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ បាននិងកំពុងរៀបចំវេទិកាសាធារណៈ និងផ្សព្វផ្សាយឯកសារថវិកា។ ទន្ទឹមនឹងនេះ អាជ្ញាធរសវនកម្មជាតិបានផ្សព្វផ្សាយរបាយការណ៍សវនកម្មស្តីពីការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ពីឆ្នាំ២០០៦-ឆ្នាំ២០១៤។
- ការកសាងសមត្ថភាព៖ វិទ្យាស្ថានសេដ្ឋកិច្ច និងហិរញ្ញវត្ថុ បាននិងកំពុងបណ្តុះបណ្តាលមន្ត្រីរាជការនៅតាមក្រសួង ស្ថាប័នលើវិស័យហិរញ្ញវត្ថុសាធារណៈ ដើម្បីគាំទ្រការអនុវត្តកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ដំណាក់កាលទី៣ និងរៀបចំផែនការកសាងសមត្ថភាព ដើម្បីគាំទ្រដល់ការអនុវត្តកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ប្រកបដោយជោគជ័យ និងចីរភាព។
- ការវិភាជថវិកាសម្រាប់គាំទ្រគណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍន៍តាមបែបប្រជាធិបតេយ្យថ្នាក់ក្រោមជាតិ៖ អគ្គលេខាធិការដ្ឋានគណៈកម្មាធិការដឹកនាំការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ, អគ្គនាយកដ្ឋានសហប្រតិបត្តិការអន្តរជាតិ និងគ្រប់គ្រងបំណុល, គណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍន៍តាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ និងដៃគូអភិវឌ្ឍន៍ នឹងរៀបចំកិច្ចប្រជុំពិភាក្សាអំពីយន្តការ និងនីតិវិធីនៃការវិភាជថវិកាជាបន្តបន្ទាប់បន្ថែមទៀត។

ជាទីបញ្ចប់ **ឯកឧត្តមបណ្ឌិតទេសរដ្ឋមន្ត្រី** បានថ្លែងអំណរគុណចំពោះ ឯកឧត្តម George Edgar និងក្រុមការងារ ដែលបានជួបសម្តែងការគួរសម និងពិភាក្សាការងារក្នុងគោលបំណងពង្រឹងការអនុវត្តកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈកម្ពុជាប្រកបដោយប្រសិទ្ធភាព និងស័ក្តិសិទ្ធភាព និងបានជូនពរដល់ឯកឧត្តម George Edgar និងក្រុមការងារ នៃសហភាពអឺរ៉ុបបំពេញភារកិច្ចនៅប្រទេសកម្ពុជាឱ្យបានជោគជ័យ។